ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤, មាត្រា១០, មាត្រា១១, មាត្រា១២, មាត្រា១៤, មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងអភិរក្សនិងអភិវឌ្ឍការប្រើភាសានិងអក្សរខ្មែរប្រកបដោយនិរន្តរភាព ព្រមទាំងរក្សាបាននូវអត្តសញ្ញាណជាតិខ្មែរ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ សរសេរកាត់ "**ក.ជ.ភ.ខ.**" ដែលជាយន្តការជាតិស្ថិតនៅក្រោមរាជបណ្ឌិត្យសភាកម្ពុជា នៃទីស្ដីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី២
## សមាសភាពរបស់ ក.ជ.ភ.ខ.

**មាត្រា៣.-**

**ក.ជ.ភ.ខ.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| - ឥស្សរបញ្ញាជនជាន់ខ្ពស់ | មួយរូប | ប្រធានកិត្តិយស |
| - ឥស្សរជនជំនាញនិងមានបទពិសោធខាងអក្សរសាស្ត្រ | មួយរូប | ប្រធាន |
| - ឥស្សរជនជំនាញខាងអក្សរសាស្ត្រ | ចំនួនបីរូប | អនុប្រធាន |
| - ប្រធានវិទ្យាស្ថាន និងស្ថាប័នឧបសម្ព័ន្ធនៃរាជបណ្ឌិត្យសភាកម្ពុជា | | សមាជិក |
| - ប្រធានគណៈកម្មការបច្ចេកទេសនៃ **ក.ជ.ភ.ខ.** | | សមាជិក |
| - តំណាងមួយរូបពីក្រសួង ស្ថាប័នពាក់ព័ន្ធ | មួយចំនួន | សមាជិក |
| - ឥស្សរជនជំនាញខាងអក្សរសាស្ត្រ | មួយចំនួន | សមាជិក |
| - ឥស្សរជនជំនាញឯកទេស | មួយចំនួន | សមាជិក |
| - តំណាងសមាគមអ្នកនិពន្ធខ្មែរ | មួយរូប | សមាជិក |

ប្រធាន អនុប្រធាន **ក.ជ.ភ.ខ.** ត្រូវមានសញ្ញាបត្របណ្ឌិត។

ប្រធាន **ក.ជ.ភ.ខ.** មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងអនុប្រធាន **ក.ជ.ភ.ខ.** មានឋានៈស្មើ អគ្គនាយក។

សមាជិក **ក.ជ.ភ.ខ.** ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។

សមាសភាព **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤.-**

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា អាចអញ្ជើញអ្នកជំនាញមួយចំនួន ជាទីប្រឹក្សារបស់ **ក.ជ.ភ.ខ.** តាមការចាំបាច់។

## ជំពូកទី៣
## ភារកិច្ចរបស់ ក.ជ.ភ.ខ.

**មាត្រា៥.-**

**ក.ជ.ភ.ខ.** មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយជាតិនៃភាសានិងអក្សរខ្មែរ
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ
- ពិនិត្យនិងសម្រេច ឱ្យមានការឯកភាពនូវពាក្យនិងបច្ចេកសព្ទដែលប្រើក្នុងភាសាខ្មែររួចមកហើយ
- កំណត់ការសរសេរ ការអាន និង និយមន័យឱ្យមានការឯកភាពក្នុងភាសាខ្មែរ
- បង្កើតពាក្យថ្មី និង សម្រេចអំពីការខ្ចីពាក្យ
- ត្រួតពិនិត្យការប្រើប្រាស់ភាសានិងអក្សរខ្មែរ
- ដាក់ជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈរាជបណ្ឌិត្យសភាកម្ពុជា ប្រកាសឱ្យប្រើជាសាធារណៈនូវលទ្ធផលនៃការកំណត់ការប្រើប្រាស់ភាសានិងអក្សរខ្មែរ
- ចងក្រងនិងផ្សព្វផ្សាយភាសានិងអក្សរខ្មែរតាមមធ្យោបាយផ្សេងៗដែលមានសិក្ខាសាលាផង
- សហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និង រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីមានវិធានការសមស្របចំពោះការប្រើភាសានិងអក្សរខ្មែរដែលបានកំណត់រួចហើយឱ្យមានប្រសិទ្ធភាព
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាពាក់ព័ន្ធនឹងការប្រើភាសានិងអក្សរខ្មែរ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជបណ្ឌិត្យសភាកម្ពុជានិងរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## កិច្ចដំណើរការការងាររបស់ ក.ជ.ភ.ខ.

**មាត្រា៦.-**

**ក.ជ.ភ.ខ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

កិច្ចប្រជុំបច្ចេកទេសរបស់ **ក.ជ.ភ.ខ.** ដឹកនាំដោយប្រធាន **ក.ជ.ភ.ខ.**។

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា មានសិទ្ធិអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធ ជាថ្នាក់ដឹកនាំ និង ថ្នាក់បច្ចេកទេស ឱ្យមកចូលរួមប្រជុំដើម្បីជួយបំភ្លឺ និង ផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់។

**មាត្រា៧.-**

**ក.ជ.ភ.ខ.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានភារកិច្ច ដូចខាងក្រោម ៖

- រៀបចំផែនការការងារ និងសម្របសម្រួលដំណើរការការងារជូន **ក.ជ.ភ.ខ.**

- រៀបចំយន្តការត្រួតពិនិត្យ និងតាមដានការប្រើប្រាស់ភាសានិងអក្សរខ្មែរ
- រៀបចំយន្តការ ចងក្រង និងផ្សព្វផ្សាយភាសានិងអក្សរខ្មែរ
- គ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃ **ក.ជ.ភ.ខ.**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពនិងលទ្ធផលការងារជូន **ក.ជ.ភ.ខ.**
- ជួយសម្រួលការងារស្រាវជ្រាវជូន **ក.ជ.ភ.ខ.**
- ទទួលអនុវត្តភារកិច្ចផ្សេង ដែលប្រធាន **ក.ជ.ភ.ខ.** ប្រគល់ជូន។

លេខាធិការដ្ឋាននៃ **ក.ជ.ភ.ខ.** ដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានយ៉ាងច្រើន ០៣ (បី) រូប ជាជំនួយការ ព្រមទាំងមានបុគ្គលិកមួយចំនួនតាមការចាំបាច់។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាននៃ **ក.ជ.ភ.ខ.** តែងតាំងដោយអនុក្រឹត្យ។

**មាត្រា៨.-**

**ក.ជ.ភ.ខ.** មានគណៈកម្មការបច្ចេកទេសសម្រាប់កិច្ចដំណើរការការងារតាមការចាំបាច់។

សមាសភាពនិងតួនាទីភារកិច្ចរបស់គណៈកម្មការបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា៩.-**

**ក.ជ.ភ.ខ.** មានសញ្ញា និង ត្រាដោយឡែករបស់ខ្លួន។

**មាត្រា១០.-**

របៀបរបបបំពេញការងាររបស់ **ក.ជ.ភ.ខ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា១១.-**

ប្រធាន អនុប្រធាន សមាជិក ទីប្រឹក្សា **ក.ជ.ភ.ខ.** និងគណៈកម្មការបច្ចេកទេស ទទួលប្រាក់ឧបត្ថម្ភប្រជុំនិងស្រាវជ្រាវតាមការកំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា១២.-**

**ក.ជ.ភ.ខ.** ត្រូវប្រើវចនានុក្រមខ្មែររៀបរៀងដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ ជាគោល។

## ជំពូកទី៥
## ប្រភពធនធានរបស់ ក.ជ.ភ.ខ.

**មាត្រា១៣.-**

**ក.ជ.ភ.ខ.** មានប្រភពធនធានមកពី ៖

- ថវិកាជាតិក្នុងគម្រោងថវិកាក្រោមខ្ទង់ថវិការបស់រាជបណ្ឌិត្យសភាកម្ពុជា
- អំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍ជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណងផ្សេងៗ។

**មាត្រា ១៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ